កិច្ចការ២៤:២៤-២៥:១២

# លោកភេលីចធ្វើសវនាការផ្ទាល់ ជាមួយសាវ័កប៉ុល

**[២៤]លុះបួនដប់ថ្ងៃក្រោយមក លោកភេលីចមកដល់ ជាមួយនឹង
ទ្រូស៊ីល ជាភរិយា ដែលជាសាសន៍យូដា រួចលោកចាត់គេទៅនាំ
ប៉ុលមក ក៏ស្តាប់គាត់អធិប្បាយពីសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ
[២៥]កំពុងដែលគាត់សំដែងពន្យល់ពីសេចក្តីសុចរិត សេចក្តីដឹងខ្នាត
នឹងសេចក្តីជំនុំជំរះដែលត្រូវមក នោះលោកភេលីចកើតមានចិត្ត
ភិតភ័យ ក៏ឆ្លើយថា ឥឡូវនេះ ឱ្យទៅសិនចុះ កាលណាមាន
ឱកាសស្រួល នោះអញនឹងហៅឯងមកទៀត (កិច្ចការ២៤:
២៤-២៥)។**

នៅពេលដែលលោកអភិបាលខេត្តភេលីច ស្តាប់ឮសាវ័កប៉ុលផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវ មន្ត្រីរូបនេះ មានការភិតភ័យជាខ្លាំង។ លោកបានជាឃាត់សាវ័កប៉ុលមិនអោយនិយាយពីព្រះបន្ទូលរបស់ព្រះអង្គបន្តទៅទៀត។ ធម្មតាមនុស្សមានបាប

ខ្លាចដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទខ្លាំងណាស់។ លោកអភិបាលខេត្តភេលីច ដែលជាមនុស្សមានបាបមួយរូបដែរ និយាយថា "ឥឡូវនេះ ឱ្យទៅសិនចុះ កាលណាមាន ឱកាសស្រួល នោះអញនឹងហៅឯងមកទៀត"។ មនុស្សមានបាបមិនដែលអនុញ្ញាត អោយមានឱកាសស្រួល ដើម្បីឮព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទេ។ នៅពេល មួយនោះ គេរកខ្ញុំទៅអធិប្បាយនៅកន្លែងប្រកួតកីឡាបាល់ទាត់។ នៅជុំវិញតារាងបាល់ មានមនុស្សចាំស្ដាប់ខ្ញុំត្រៀបត្រា។ នៅចន្លោះពេលប្រកួតលើកទីមួយ និងលើកទីពីរ គេអោយខ្ញុំអធិប្បាយព្រះបន្ទូលព្រះ។ កំពុងតែមានមនុស្សស្ដាប់យ៉ាងយកចិត្តទុកដាក់ អាជ្ញាកណ្ដាលបីនាក់ខំផ្លុំកញ្ចែរន្ធើនៗសម្ដុតដល់ពួកកីឡាករ អោយប្រញាប់ចូលមក ប្រកួត។ ខ្ញុំចង់និយាយមួយនាទីកន្លះថែមទៀត ប៉ុន្តែគេចេះតែផ្លុំកញ្ចែថែមហើយថែម ទៀត ខ្ញុំក៏បញ្ចប់សេចក្តីអធិប្បាយរបស់ខ្ញុំស្តីអំពីព្រះអម្ចាស់យេស៊ូវទៅ។ ដូច្នេះ មនុស្ស មានបាបមិនដែលផ្ដល់ឱកាសស្រួលអោយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ជ្រាបចូល ទៅក្នុងចិត្តខ្លួន ក៏ដូចជាមិនអោយជ្រាបចូលទៅក្នុងចិត្តរបស់អ្នកដទៃទៀតដែរ។

នៅក្នុងខណៈនេះ លោកអភិបាលខេត្តភេលីច បានហៅសាវ័កប៉ុលទៅជួបជា មួយនឹងលោកជាលើកទីពីរហើយ។ នៅក្នុងគំនិតរបស់មន្ត្រីរូបនេះ ការហៅសាវ័កប៉ុល ចូលទៅជួប គឺចង់អោយសាវ័កប៉ុលសូកប៉ាន់ ដើម្បីអោយលោករួចចេញពីមន្ទីរឃុំ ឃាំង។ ប៉ុន្តែ ចំណែកសាវ័កប៉ុលវិញ មានគោលបំណងតែម្យ៉ាងគត់ គឺចង់ផ្សាយដំណឹង ល្អពីព្រះអម្ចាស់យេស៊ូវប្រាប់ដល់លោកអភិបាលខេត្តរូបនេះ។ នៅពេលសាវ័កប៉ុលចូល ទៅជួបជាមួយនឹងអភិបាលខេត្តរូបនេះ លោកធ្វើទីបន្ទាល់ពីចេស្ដារបស់ព្រះអម្ចាស់

យេស៊ូវគ្រីស្ទនៅក្នុងជីវិតរបស់លោក។

នៅក្នុងព្រះគម្ពីរយើងមិនឃើញថា មានសាច់រឿងដែលនិយាយអំពីកិរិយាអាក្រក់របស់លោកអភិបាលខេត្តភេលីចនេះទេ។ បើនៅក្នុងប្រវត្តិសាស្ត្ររបស់សកលលោក មានចារទុកអំពីកិរិយាអាក្រក់របស់មន្ត្រីរូបនេះ។ ពាក្យថាភេលីច ប្រែថាសម្រើប។ លោកអភិបាលខេត្តភេលីច គឺជាអភិបាលខេត្តដែលមានសម្រើបគ្រប់បែបយ៉ាង គឺលោកមានសម្រើបខាងកាមតណ្ហា លោកមានសម្រើបខាងអំណាច លោកមានសម្រើបខាងទ្រព្យសម្បត្តិ។ អ្នកប្រវត្តិវិទូជាតិរ៉ូមមួយរូបនាមថាសឺតតឹស បង្ហើបអោយយើងស្គាល់អំពីកិរិយាប្រព្រឹត្តរបស់លោកអភិបាលខេត្តភេលីចថា "លោកភេលីចជាមនុស្សសាហាវយង់ឃ្នង គ្មានសីលធម៌នៅក្នុងខ្លួន ព្រមទាំងប្រើអំណាចប្រៀបឧបមាដូចជាស្ដេចក្រាញ់ ចាត់ទុកមនុស្សដទៃទៀតថោកទាបជាងខ្ញុំកញ្ជះដាច់ថ្លៃរបស់ខ្លួនទៅទៀត"។ ពេលដែលគេយកសាវ៉កប៉ុលទៅឃុំនៅក្នុងទីក្រុងសេសារា លោកស្ថិតនៅក្នុងកណ្ដាប់ដៃមន្ត្រីមួយរូបដែលមានលក្ខណៈដូចអ្នកប្រវត្តិវិទូជាតិរ៉ូម បានមានប្រសាសន៍ខាងលើ។ ប៉ុន្តែ ទោះជាមន្ត្រីរូបនេះ មានកិរិយាប្រព្រឹត្តមិនសមជាមនុស្សជាតិយ៉ាងដូច្នេះក៏ដោយ ព្រះគម្ពីរមិនបានសម្ដែងពីកិរិយាអាក្រក់ណាមួយរបស់មន្ត្រីរូបនេះឡើយ។

ចំណែកលោកជំទាវរបស់លោកអភិបាលខេត្តភេលីចនាមទ្រូស៊ីលវិញ ប្រវត្តិសាស្ត្រសកលលោកបានចែងពីអាកប្បកិរិយារបស់នាង ថាជាមនុស្សអាក្រក់ណាស់ដែរ។ នាងត្រូវជាព្រះរាជបុត្រីរបស់ព្រះរាជាហេរ៉ូឌអ័គ្រីប៉ាទីមួយ។ បិតារបស់នាងចាប់លោកយ៉ាកុបទៅកាប់សម្លាប់ដោយដាវ ដូចយើងបានឃើញនៅក្នុងគម្ពីរកិច្ចការ១២:១-២។

ព្រះជេដ្ឋារបស់នាងបានយកលោកយ៉ូហាន-បាទីស្ទទៅកាត់ក រួចហើយយកក្បាលលោកដាក់លើថាស។ ចំណែកព្រះបិតុលារបស់នាងវិញ សម្លាប់កូនក្មេងអាយុពីរឆ្នាំចុះក្រោម ដោយប៉ងធ្វើឃាតព្រះអម្ចាស់យេស៊ូវ បន្ទាប់ពីទ្រង់ប្រសូតមកក្នុងលោកីយ៍នេះ។

ប្ដីប្រពន្ធខាងលើ គឺលោកអភិបាលខេត្តភេលីច និងនាងទ្រូស៊ីល គឺជាមនុស្សដែលមានកិរិយាសាហាវយង់ឃ្នងទាំងពីររូប។ អ្នកទាំងពីរមិនដែលស្ដាប់សេចក្ដីបង្រៀនប្រៀនប្រដៅរបស់បាអាចារ្យណាម្នាក់ឡើយ។ នៅពេលដែលសាវ័កប៉ុលអធិប្បាយអោយមនុស្សទាំងរយទាំងពាន់នាក់ស្ដាប់ អ្នកទាំងពីរនាក់ មិនខ្វីយកត្រចៀកស្ដាប់ដល់ការបង្ហាត់បង្រៀនព្រះបន្ទូលរបស់សាវ័កប៉ុលដែរ។ អ្នកទាំងពីរនាក់មានឱកាសគ្រប់គ្រាន់ជាងជនណាទាំងអស់ ពោលគឺបានហៅអោយសាវ័កប៉ុល ដែលជាគ្រូអធិប្បាយដ៏ល្បីល្បាញនៅក្នុងព្រះគម្ពីរ មកពន្យល់ព្រះបន្ទូលអោយគេស្ដាប់។ គាត់បានមានឱកាសយ៉ាងទូលំទូលាយ ដើម្បីសម្រេចចិត្តជឿដល់ព្រះអម្ចាស់យេស៊ូវ។ ព្រះជាម្ចាស់ប្រទានឱកាសអោយអ្នកទាំងពីរនេះស្គាល់ទ្រង់ជាបរិបូរ។ បើតាមទំនោរចិត្ត លោកអភិបាលខេត្តភេលីចចង់បើកចិត្តទទួលព្រះអម្ចាស់យេស៊ូវ បន្ទាប់ពីយល់ដល់ដំណឹងល្អដែលសាវ័កប៉ុលបានអធិប្បាយរួចហើយ។ ប៉ុន្តែ មន្ត្រីរូបនេះមិនបានសម្រេចចិត្តនៅក្នុងពេលនោះទេ ដ្បិតលោករង់ចាំឱកាសល្អ។ លោកអ្នកបងប្អូនអើយ មនុស្សមានបាបមិនដែលផ្ដល់អោយមានឱកាសល្អសម្រាប់អោយខ្លួនឯង និងអ្នកដទៃដើម្បីឮដំណឹងល្អពីសេចក្ដីសង្គ្រោះព្រះអម្ចាស់យេស៊ូវឡើយ។ មនុស្សមិនអាចបង្កើតឱកាសបានទេ តែព្រះជាអ្នកផ្ដល់ឱកាសដល់មនុស្សលោក ប៉ុន្តែមនុស្សលោកត្រូវឆក់ឱកាសនោះ ទុកសម្រាប់ជា

ប្រយោជន៍ដល់ព្រលឹងរបស់ខ្លួនទាក់ទងនឹងជីវិតអស់កល្បជានិច្ច។

សាវ័កប៉ុលពន្យល់សេចក្តីបីយ៉ាងដល់លោកអភិបាលខេត្តភេលីច និងភរិយារបស់លោក គឺនាងទ្រូស៊ីល។ ទីមួយ សាវ័កប៉ុលពន្យល់អ្នកទាំងពីរពីសេចក្តីសុចរិត មួយទៀតពីសេចក្តីដឹងខ្នាត ហើយមួយទៀតពីសេចក្តីជំនុំជំរះ។ សេចក្តីសុចរិត គឺជាសេចក្តីសុចរិតដែលព្រះអម្ចាស់យេស៊ូវប្រទានមកអោយមនុស្សលោក។ មនុស្សគ្រប់រូបមិនអាចទទួលសេចក្តីសុចរិតដោយសារគ្រាន់តែធ្វើតាមក្រឹត្យវិន័យនានា អោយបានគ្រប់លក្ខណៈនោះទេ។ ដ្បិតមនុស្សលោកមិនអាចប្រកាសខ្លួនថាជាមនុស្សគ្រប់លក្ខណៈបានទេ។ ដោយសារមនុស្សមិនអាចផ្តល់សេចក្តីសុចរិតអោយខ្លួនឯងបាន បានជាព្រះវរបិតាបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ អោយមកសុគតនៅលើឈើឆ្កាង ដើម្បីអោយអស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ ទ្រង់រាប់ថា ជាជនសុចរិតក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គោលទ្ធិនេះដកស្រង់ចេញពីក្នុងគម្ពីររ៉ូម៣:២២។

មិនតែប៉ុណ្ណោះ សាវ័កប៉ុលបង្រៀនអំពីសេចក្តីដឹងខ្នាត។ លោកភេលីចហើយនិងលោកស្រីទ្រូស៊ីលរស់នៅដាច់ឆ្ងាយពីភាពដឹងខ្នាត។ មនុស្សទាំងពីររូបនេះ ជាមនុស្សសាហាវយង់ឃ្នង ព្រមទាំងប្រើអំណាចជាងស្តេចក្រាញ់ទៅទៀត។ តើការដឹងខ្នាតមានប្រយោជន៍អ្វីសម្រាប់មនុស្សប្រភេទនោះ? ចំណុចមួយទៀត ដែលសាវ័កប៉ុលបង្រៀនដល់មន្ត្រីជាន់ខ្ពស់ពីរនេះ គឺការជំនុំជំរះដែលត្រូវមកក្នុងពេលអនាគតខាងមុខ។ សាវ័កប៉ុលបញ្ជាក់ថា បើមន្ត្រីទាំងប្តីប្រពន្ធទាំងពីររូបនេះ មិនព្រមទទួលសេចក្តីសុចរិតរបស់ព្រះយេស៊ូវ មិនព្រមរស់នៅដោយដឹងខ្នាត នោះមិនមានមធ្យោបាយណាគេចរួចអំពី

សេចក្តីជំនុំជំរះដែលព្រះយេស៊ូវយាងមកគង់នៅលើបល្ល័ង្កស ពេលទ្រង់កាត់ទោសអស់ទាំងមនុស្សរស់និងមនុស្សស្លាប់ផងទេ។ គោលទ្ធិនេះដកស្រង់ចេញពីក្នុងគម្ពីរវិវរណៈ ២០: ១១-១៥។

សេចក្តីបង្រៀនខាងលើបន្សល់ទុកនូវសេចក្តីពិតសម្រាប់អោយយើងទាំងអស់គ្នាយកមកអនុវត្ត។ លោកអ្នកបងប្អូនទាំងឡាយអើយ លោកអ្នកជឿពិតប្រាកដថា នៅក្នុងជំរៅចិត្តរបស់លោកអ្នក លោកអ្នកមិនមែនជាមនុស្សគ្រប់លក្ខណៈមែនទេ។ បើយ៉ាងដូច្នោះមែន ព្រះបន្ទូលព្រះអម្ចាស់យេស៊ូវសម្តែងថា លោកអ្នកជាមនុស្សមានបាប។ ប៉ុន្តែលោកអ្នកអាចជ្រើសរើសដោះស្រាយអំពើបាបរបស់លោកអ្នកបាន។ លោកអ្នកអាចលីសែងអំពើបាបខ្លួនឯងផ្ទាល់ ឬមួយក៏លោកអ្នកផ្ទេរអំពើបាបរបស់លោកអ្នកថ្វាយដល់ព្រះអម្ចាស់យេស៊ូវអោយទ្រង់លីសែងជំនួសវិញ។ បើលោកអ្នកផ្ទេរអំពើបាបរបស់លោកអ្នកថ្វាយដល់ព្រះយេស៊ូវគ្រីស្ទ រួចហើយជឿដល់ព្រះអង្គថាទ្រង់សុគតបង់សងថ្លៃអំពើបាបរបស់លោកអ្នក នោះលោកអ្នកមិនចាំបាច់ត្រូវទទួលការជំនុំជំរះនៅក្នុងពេលខាងមុខទេ។ ផ្ទុយទៅវិញ បើលោកអ្នកសម្រេចចិត្តថា សុខចិត្តលីសែងអំពើបាបរបស់លោកអ្នកខ្លួនឯង លោកអ្នកនឹងត្រូវយកអំពើបាបនោះទៅទូទាត់ជាមួយនឹងព្រះអម្ចាស់យេស៊ូវនៅថ្ងៃដែលទ្រង់យាងមកជំនុំជំរះផែនដី នៅពេលខាងមុខ។

ឥឡូវ សូមយើងបែរត្រឡប់ទៅមើលកិរិយារបស់លោកអភិបាលខេត្តភេលីចដែលរកឱកាសស្រួល សម្រាប់ស្តាប់ដំណឹងល្អនៅពេលក្រោយទៀត។ នៅពេលសម្តេចសង្ឃអាន្នាំនាស និងពួកចាស់ទុំនាំមេធាវីដើមចោទមកចោទប្រកាន់ដល់សាវ័កប៉ុល

លោកភេលីចបានហៅសាវ័កប៉ុលអោយមកបំភ្លឺ ពីពាក្យចោទប្រកាន់ទាំងអម្បាលមាណនោះ។ លោកភេលីចយល់ភ្លាមថា រឿងចោទប្រកាន់ទាំងអម្បាលមាណ ឥតទាក់ទងអ្វីជាមួយនឹងច្បាប់របស់រាជការរ៉ូមទេ។ តាមពិតបើគ្រាន់តែចោទប្រកាន់ដល់សាវ័កប៉ុលត្រឹមតែចំណុចប៉ុន្មានយ៉ាងនោះ សាវ័កប៉ុលអាចរួចខ្លួនទៅជាពលរដ្ឋធម្មតាបានហើយ។ ប៉ុន្តែ លោកអភិបាលខេត្តភេលីច គឺជាអ្នកនយោបាយដែលមិនចង់ធ្វើអោយសាសន៍យូដាមានការអាក់អន់ចិត្តទេ ពីព្រោះសាសន៍យូដា គឺជាអ្នកគាំទ្រលើកលោកឡើងអោយធ្វើជាចៅហ្វាយខេត្តនៅក្នុងខេត្តរបស់ខ្លួន។ ធម្មតាអ្នកនយោបាយទោះជាតិសាសន៍ណា សម័យណា ភាគច្រើនមិនខុសពីលោកអភិបាលខេត្តភេលីចដែរ។ លោកហៅសាវ័កប៉ុលមកជួបជាច្រើនលើកច្រើនសារ ឯសាវ័កប៉ុលទៀតសោត ក៏បានផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវដល់មន្ត្រីរូបនេះ។ ទោះបីមន្ត្រីរូបនោះយល់ច្បាស់អំពីព្រះបន្ទូលរបស់ព្រះអង្គយ៉ាងណាក៏ដោយ លោកចេះតែថា ចាំរកឱកាសស្រួលទើបទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាអង្គសង្គ្រោះ។

នៅក្នុងរយៈពេល២០០០ឆ្នាំកន្លងមកហើយ មានមនុស្សច្រើនកោដិរូបដែលស្លាប់ទៅដោយសាររង់ចាំឱកាសស្រួល ដើម្បីឮព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទម្តងទៀត។ អ្នកខ្លះនិយាយថា ខ្ញុំយល់ពីព្រះបន្ទូលរបស់ព្រះអង្គហើយ ប៉ុន្តែ ខ្ញុំចាំកូនខ្ញុំធំៗដឹងក្តីអស់ គេចេញពីធ្វើការអស់ ទើបខ្ញុំចូលទៅទទួលព្រះអម្ចាស់យេស៊ូវ។ អ្នកខ្លះទៀតនិយាយថា ខ្ញុំមិនទាន់រកស៊ីមានបានគ្រប់គ្រាន់នៅឡើយ ខ្ញុំមិនអាចកាន់សីលរបស់ព្រះយេស៊ូវបាន។ មនុស្សគ្រប់រូបមានមូលហេតុរាប់រយជំពូក ចេះតែដោះសាចាំមានឱកាស

ស្រួល ទើបទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះរបស់ខ្លួន។ លោកអ្នកបងប្អូនអើយ កាលណាយើងចេះតែចាំរកឱកាស ឱកាសនោះចេះតែកន្លងបាត់ទៅ។ លុះឱកាសចេះតែកន្លងបាត់ទៅ ជីវិតរបស់យើងក៏ត្រូវស្លាប់ទៅ ដោយគ្មានព្រះអម្ចាស់យេស៊ូវគ្រីស្ទ យាងទៅជាមួយនឹងយើងដែរ។ កាលណាយើងស្លាប់ដោយគ្មានព្រះអម្ចាស់យេស៊ូវយាងទៅជាមួយ យើងត្រូវទទួលរងទណ្ឌកម្មអំពើបាបទាំងអម្បាលមាណដែលយើងបានប្រព្រឹត្តនៅលើលោកនេះដោយខ្លួនឯងហើយ។ បើយើងទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះនៅពេលយើងរស់នៅ យើងមិនត្រូវជំនុំជំរះនៅក្នុងពេលខាងមុខទេ ដ្បិតព្រះយេស៊ូវទទួលការជំនុំជំរះនៅលើឈើឆ្កាងជួសយើងរួចអស់ហើយ។ ស្តីអំពីការរង់ចាំឱកាសល្អទើបទទួលព្រះអម្ចាស់យេស៊ូវ អភិបាលខេត្តភេលីច និងនាងទ្រូស៊ីល ក៏មិនមានឱកាសនោះ។ ឯមនុស្សរាប់លានរាប់កោដិនាក់ ធ្លាប់រស់នៅក្នុង២០០០ឆ្នាំកន្លងមកដែលរង់ចាំឱកាសល្អដើម្បីទទួលព្រះអម្ចាស់យេស៊ូវ ក៏គ្មានឱកាសនោះដែរ។ ចំណែកលោកអ្នកវិញ តើលោកអ្នករង់ចាំឱកាសល្អ ទើបទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះឬ? បើយ៉ាងដូច្នោះមែន សូមប្រយ័ត្នផង ក្រែងលោឱកាសនោះមិនចេះមកដល់ លោកអ្នកបងប្អូនក៏បាត់ឱកាសដោយបាត់បង់ជីវិតពីលោកនេះទៅ។ សូមលោកអ្នកកុំចាំបាច់រង់ចាំឱកាសល្អ ដើម្បីទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាអង្គសង្គ្រោះឡើយ។ បើលោកអ្នកឮព្រះបន្ទូលថ្ងៃនេះ សូមទទួលថ្ងៃនេះចុះ ដ្បិតឱកាសបានមកដល់លោកអ្នកបងប្អូននៅថ្ងៃនេះហើយ។

**លោកក៏សង្ឃឹមថា ប៉ុលនឹងយកប្រាក់មកសូកលោក ឱ្យលែងចេញដែរ ហេតុនោះបានជាលោកឱ្យគេនាំគាត់មកពិគ្រោះកាន់តែញឹកញយឡើង (កិច្ចការ២៤:២៦)។**

លោកអភិបាលខេត្តភេលីចជាអ្នកនយោបាយពិតប្រាកដមែន។ លោកហៅសាវ័កប៉ុលមកជួបជាញឹកញាប់ មិនមែនចង់ដោះលែងលោកប៉ុលទេ ពីព្រោះបើតាមច្បាប់យុត្តិធម៌ក្នុងតុលាការ លោកប៉ុលមិនមែនជាមនុស្សជាប់ទោសអ្វីទេ។ ប៉ុន្តែមន្ត្រីរូបនេះ ហៅសាវ័កប៉ុលមកពិភាក្សាញឹកញាប់ ពីព្រោះមន្ត្រីរូបនេះចង់អោយសាវ័កប៉ុលសូកប៉ាន់ដល់គាត់។

**ប៉ុន្តែ លុះបានកន្លងមកបាន២ឆ្នាំហើយ នោះមានលោកព័រគាស-ភេស្ទុស មកឈរជំនួសលោកភេលីច ហើយដោយព្រោះលោកភេលីច ចង់បានបំណាច់ ចំពោះសាសន៍យូដាផង បានជាលោកទុកឱ្យប៉ុលជាប់គុកនៅ (កិច្ចការ២៤:២៧)។**

លោកអភិបាលខេត្តភេលីច មិនបានសម្រេចវត្ថុបំណងរបស់ខ្លួន ដោយសារសាវ័កប៉ុលមិនព្រមសូកប៉ាន់ ដើម្បីអោយរួចចេញពីគុកឡើយ។ លោកមន្ត្រីរូបនោះកាន់ដងកាំបិត អោយសាវ័កប៉ុលកាន់ផ្លែកាំបិត។ ដោយសារមន្ត្រីរូបនោះមានអំណាច

នៅក្នុងរាជការរ៉ូម គាត់ក៏ទុកសាវ័កប៉ុលអោយនៅជាប់ក្នុងមន្ទីរឃុំឃាំង ទោះបីសាវ័កប៉ុលជាមនុស្សមានសេរីភាពដូចពលរដ្ឋដទៃក៏ដោយ។ គេតែងតែនិយាយថា ប្រព័ន្ធយុត្តិធម៌សាសន៍រ៉ូម មានភាពយុត្តិធម៌ខ្លាំងណាស់។ បើអ្នកប្រើច្បាប់តុលាការសាសន៍រ៉ូមតាមភាពយុត្តិធម៌មែន សាវ័កប៉ុលដែលច្បាប់រកឃើញជាប់ទោសដោយបទណាមួយ លោកត្រូវគេយកទៅកាត់ទោសប្រហារជីវិត។ ប៉ុន្តែបើលោកគ្មានទោសអ្វីទេ ត្រូវដោះលោកអោយរួចចេញពីមន្ទីរឃុំឃាំង។ ប៉ុន្តែ ប្រព័ន្ធតុលាការសាសន៍រ៉ូម ទោះបីជាមហាអំណាចរបស់សកលលោកក៏ដោយ ក៏ស្ថិតនៅក្នុងប្រព័ន្ធពុករលួយដែរ។ សាវ័កប៉ុលមិនត្រូវជាប់ទោសដោយគ្មានកំហុស រហូតដល់ទៅពីរឆ្នាំយ៉ាងដូច្នេះទេ។ ត្រង់នេះហើយដែលហៅថា អំពើអយុត្តិធម៌លេបអំពើយុត្តិធម៌បាត់ ទោះក្នុងប្រទេសមហាអំណាចក៏ដោយ។

# ជំពូក ២៥

***ខាងចនា*** *សាវ័កប៉ុលធ្វើបន្ទាល់នៅមុខលោកភេស្ទុស*
*ព្រះរាជាអគ្រីសប៉ា និងព្រះនាងបេរីនិសមកលែងលោកភេស្ទុស*
*សាវ័កប៉ុលធ្វើបន្ទាល់នៅមុខលោកភេស្ទុសនិងព្រះរាជាអគ្រីសប៉ា*

យើងឃើញថា សាវ័កប៉ុលត្រូវគេយកទៅឃុំឃាំងដោយអយុត្តិធម៌ជាទីបំផុតអស់រយៈពេលពីរឆ្នាំកន្លងមកហើយ។ ឥឡូវនេះ លោកអភិបាលខេត្តភេលីច បានចប់អាណាត្តិរបស់លោកធ្វើជាចៅហ្វាយខេត្តនៅខេត្តយូដា។ លោកភេស្ទុស គឺជាចៅហ្វាយខេត្តទទួលតំណែងបន្តពីលោកចៅហ្វាយខេត្តមុន។ លោកភេស្ទុសបានហៅសាវ័កប៉ុលអោយទៅពន្យល់រឿងក្តីទាំងអម្បាលមាណ ដែលបណ្តាលអោយគេចាប់លោកយកមកដាក់នៅក្នុងមន្ទីរឃុំឃាំង។

កន្លងមកយើងឃើញសាវ័កប៉ុលឈរពន្យល់រឿងក្តីនោះ ដល់ពួកបាតុករនៅក្នុងទីក្រុងយេរូសាឡិម។ ក្រោយមកទៀត លោកពន្យល់រឿងក្តីរបស់លោកនៅមុខពួកគណៈសង្ឃ។ លុះដល់គេបញ្ជូនលោកមកក្នុងទីក្រុងសេសារា លោកមានឱកាសធ្វើបន្ទាល់ប្រាប់ដល់លោកអភិបាលខេត្តភេលីច និងភរិយារបស់លោក គឺនាងទ្រូស៊ីល។ អ្នកទាំងពីររូបនេះ បានហៅសាវ័កប៉ុលទៅជួបយ៉ាងញឹកញាប់ មិនមែនដោយសារចង់រំដោះលែងគាត់ទេ គឺចង់បានសំណូកសូកប៉ាន់ពីលោកប៉ុលវិញ។ មន្ត្រីអភិបាលខេត្តភេលីច

ហើយនិងភរិយាបានត្រូវផ្លាស់ចេញពីខេត្តនោះបាត់ទៅ។ ឥឡូវ លោកភេស្ទុសបានចូលមកកាន់តំណែងបន្តបន្ទាប់ទៀត។ លោកភេស្ទុសបានហៅសាវ័កប៉ុលទៅពន្យល់រឿងក្តីដែលគេចោទប្រកាន់ដល់លោក។ ក្រោយមកទៀត សាវ័កប៉ុលនឹងត្រូវទៅឈរនៅចំពោះមុខព្រះរាជអគ្រីសប៉ា ដើម្បីធ្វើទីបន្ទាល់អំពីព្រះអម្ចាស់យេស៊ូវ។ សាវ័កប៉ុលមានឱកាសឈរធ្វើទីបន្ទាល់ពីព្រះអម្ចាស់យេស៊ូវនៅមុខឥស្សរជនជាន់ខ្ពស់ និងមន្ត្រីគ្រប់ជាន់ថ្នាក់ ដើម្បីអោយគេឮពីដំណឹងល្អពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ខ្ញុំជឿថា សាវ័កប៉ុលច្បាស់ជាហត់នឿយជាមិនខាន អំពីដំណើរដែលគេយកទៅសួរយ៉ាងញឹកញាប់ដូច្នេះ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ លោកជ្រាបច្បាស់អំពីមូលហេតុដែលលោកចាំបាច់ត្រូវតែឈរនៅមុខឥស្សរជន និងមន្ត្រីគ្រប់ជាន់ថ្នាក់។ នៅក្នុងគម្ពីរកិច្ចការ៩:១៥ ព្រះជាម្ចាស់រំឭកដល់សាវ័កប៉ុល ពីមូលហេតុដែលព្រះអម្ចាស់បានត្រាស់ហៅលោកអោយមកជឿដល់ព្រះអង្គ។ នៅក្នុងគម្ពីរនោះព្រះអម្ចាស់មានបន្ទូលថា "...ពីព្រោះអ្នកនោះ (សាវ័កប៉ុល) ជាប្រដាប់រើសតាំងដល់ខ្ញុំ សំរាប់នឹងប្រកាសឈ្មោះខ្ញុំដល់ពួកសាសន៍ដទៃនឹងពួកស្តេចហើយនិងពួកកូនចៅសាសន៍អ៊ីស្រាអែលផង" (កិច្ចការ៩:១៥)។ ដោយសារមូលហេតុនេះ សាវ័កប៉ុលមានការរីករាយយ៉ាងខ្លាំង ដោយមានឱកាសបម្រើព្រះអង្គតាមផែនការរបស់ទ្រង់ សម្រាប់ជីវិតរបស់លោក។

រៀងរាល់ពេលដែលសាវ័កប៉ុលឈរនៅមុខឥស្សរជន និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ លោកតែងតែនិយាយប្រាប់គេអំពីព្រះយេស៊ូវដែលទ្រង់បានប្រើលោក។ ម្យ៉ាងទៀត លោកធ្វើទីបន្ទាល់ដល់អ្នកទាំងនោះ ដោយចិត្តឧស្សាហ៍ និងមានការប្រាកដនៅ

ក្នុងចិត្តផង។ មន្ត្រីគ្រប់ជាន់ថ្នាក់បានឮដំណឹងល្អតាមរយៈសាវ័កប៉ុល។ ប៉ុន្តែដើម្បីអោយមន្ត្រីគ្រប់ជាន់ថ្នាក់ឮដំណឹងល្អយ៉ាងដូច្នេះ សាវ័កប៉ុលត្រូវមានការលំបាក ពោលគឺគេយកលោកទៅឃុំក្នុងមន្ទីរឃុំឃាំងដោយអយុត្តិធម៌។ ក្រោយមកទៀត ក្នុងរយៈពេលពីរឆ្នាំយើងមិនបានដឹងអំពីជីវិតរបស់សាវ័កប៉ុលនៅក្នុងគុកថា មានសុខទុក្ខយ៉ាងណាទេ។ មិនដឹងទាល់តែសោះ រីឯព្រះជាម្ចាស់ក៏មិនបានអនុញ្ញាតអោយយើងទាំងអស់គ្នាដឹងអំពីដំណើរនោះដែរ។ លោកអ្នកបងប្អូនអើយ សូម្បីសាវ័កប៉ុល ដែលជាសាវ័ករបស់ព្រះជាម្ចាស់ផ្ទាល់ ក៏មានពេលដែលកិច្ចការរបស់លោកត្រូវបង្អាក់បន្ទច់មួយរយៈពេលយ៉ាងដូច្នោះដែរ។ បើយើងជាអ្នកបម្រើព្រះអង្គ មានពេលដែលកិច្ចការរបស់យើងត្រូវបង្អាក់ តើរឿងនេះមិនគួរជារឿងដែលលើកទឹកចិត្តដល់យើងគ្រប់គ្នាទេឬ?

## សាវ័កប៉ុលធ្វើបន្ទាល់នៅមុខ
## លោកភេស្ទុស

**១ លុះកាលលោកភេស្ទុសបានចូលមកក្នុងខេត្ត នោះក្រោយ៣ថ្ងៃ**
**លោកក៏ឡើងពីសេសារា ទៅឯក្រុងយេរូសាឡិម ២ ឯពួកសង្គ្រាជ**
**នឹងពួកមេសាសន៍យូដា គេចូលទៅជំរាបលោកពីដំណើរប៉ុល**
**៣ ហើយសូមអង្វរឲ្យលោកអនុញ្ញាតចាត់គេ ឲ្យទៅនាំគាត់មកក្រុង**

**យេរូសាឡិមវិញ ពីព្រោះគេមត់គ្នានឹងសំឡាប់គាត់តាមផ្លូវ "តែលោកភេស្ទុសឆ្លើយថា ត្រូវតែឃុំប៉ុលទុកនៅក្រុងសេសារានោះចាំបន្តិចទៀត ខ្លួនខ្ញុំនឹងទៅឯណោះដែរ (កិច្ចការ២៥:១-៨)។**

បើតាមសាច់រឿងដែលកើតឡើងនៅក្នុងអត្ថបទដែលយើងទើបនឹងអាន ខ្ញុំយល់ថា លោកអភិបាលខេត្តភេស្ទុសយល់អំពីស្ថានភាពរបស់សាវ័កប៉ុល។ មុននឹងលោកអភិបាលខេត្តភេលីចប្តូរតំណែងចេញបាត់ទៅ លោកពិតជាពន្យល់អំពីសាច់រឿងដែលគេចាប់សាវ័កប៉ុលមកឃុំឃាំង ព្រមទាំងពន្យល់អំពីស្ថានភាពដែលទាក់ទងជាមួយនឹងការចោទប្រកាន់ទាំងអម្បាលមាណដល់សាវ័កប៉ុល។ លោកភេស្ទុសយល់ថា មូលហេតុដែលគេនាំសាវ័កប៉ុលមកឃុំទុកនៅក្នុងក្រុងសេសារា គឺការពារកុំអោយសាសន៍យូដាសម្លាប់លោកក្រៅច្បាប់តុលាការ។ ដូច្នេះហើយ បានជានៅពេលសាសន៍យូដា សូមអោយគេនាំសាវ័កប៉ុលត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ លោកឆ្លើយទៅគេវិញថា "...ត្រូវតែឃុំប៉ុលទុកនៅក្រុងសេសារានោះ ចាំបន្តិចទៀតខ្លួនខ្ញុំនឹងទៅឯណោះដែរ"។ លោកអភិបាលខេត្តភេស្ទុសជាមន្ត្រីមួយរូបទៀត ដែលចូលចិត្តរស់នៅទីក្រុងសេសារា ជាជាងរស់នៅទីក្រុងយេរូសាឡិម។

ចំណែកឯសត្រូវរបស់សាវ័កប៉ុល មិនចង់បង្ហាតពេលទុកអោយសាវ័កប៉ុលរស់នៅដូច្នេះឡើយ។ គេចង់អោយលោកអភិបាលខេត្តថ្មី កាត់ទោសសាវ័កប៉ុលអោយបានឆាប់ៗ។ ខ្ញុំយល់ថា លោកភេស្ទុសជ្រាបអំពីដំណើរដែលគេនាំគ្នាធ្វើឧបាយកលស្កាត់ផ្លូវ

ដើម្បីធ្វើឃាតសាវ័កប៉ុលដោយសម្ងាត់។ ក្នុងគម្ពីរមិនបាននិយាយយ៉ាងដូច្នោះទេ ប៉ុន្តែ បើតាមការដែល លោកមិនបណ្តោយអោយគេនាំសាវ័កប៉ុលទៅកាន់ទីក្រុងយេរូសាឡិម វិញ យើងអាចសន្និដ្ឋានបានថា លោកភេស្ទុសជ្រាបច្បាស់អំពីផែនការសម្ងាត់របស់ពួក សាសន៍យូដា។

> **៥ដូច្នេះ លោកប្រាប់ថា ចូរអស់អ្នកដែលមានអំណាចក្នុងពួកអ្នក**
> **រាល់គ្នា ចុះទៅជាមួយគ្នា បើមនុស្សនោះមានទោសអ្វី នោះត្រូវ**
> **ឱ្យចោទប្រកាន់វាចុះ ៦កាលបានស្នាក់នៅក្នុងទីក្រុងគេជាង១០ថ្ងៃ**
> **នោះក៏ចុះទៅឯសេសារាវិញ ដល់ថ្ងៃស្អែកឡើង លោកអង្គុយ**
> **នៅទីជំនុំជំរះក្តី ហើយបង្គាប់ឱ្យគេនាំប៉ុលមក ៧លុះគាត់ចូលមក**
> **ដល់ នោះពួកសាសន៍យូដា ដែលចុះពីក្រុងយេរូសាឡិមមក គេ**
> **ឈរនៅជុំវិញ ក៏ចោទគាត់ពីរឿងធ្ងន់ៗជាច្រើន ដែលគេមិនអាច**
> **នឹងរកភស្តុតាងបាន (កិច្ចការ២៥:៥-៧)។**

គេនាំសាវ័កប៉ុលទៅទីកាត់ក្តី ដើម្បីអោយលោកឆ្លើយដោះសា អំពីការចោទប្រកាន់ទាំងអម្បាលមាណដល់រូបលោក។ ឱកាសនោះហើយ ជាឱកាសល្អសម្រាប់សាវ័កប៉ុល ដើម្បីធ្វើទីបន្ទាល់អំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**ប៉ុន្តែគាត់ដោះសាខ្លួនថា ខ្ញុំប្របាទមិនបានធ្វើបាបអ្វីសោះ ទោះនឹងក្រឹត្យវិន័យរបស់សាសន៍យូដា ឬនឹងព្រះវិហារ ឬនឹងសេសារក្តី តែលោកភេស្ទុសចង់បានបំណាច់ចំពោះពួកសាសន៍យូដា ក៏សួរទៅប៉ុលថា ឯងសុខចិត្តឡើងទៅឯក្រុងយេរូសាឡិម ឲ្យអញជំនុំជំរះឯងពីដំណើរនេះឬទេ (កិច្ចការ២៥:៨-៩)។**

លោកអភិបាលខេត្តភេស្ទុស ក៏មិនមែនជាមនុស្សអន់ណយប៉ុន្មានដែរ។ ធម្មតា ទំរាំបានស៊ីបុណ្យចៅហ្វាយខេត្ត លោកត្រូវឆ្លងកាត់ការប្រកួតប្រជែងច្រើនយ៉ាងណាស់។ ឥឡូវ លុះបានស៊ីបុណ្យជាចៅហ្វាខេត្តហើយ តើលោកមិនត្រូវប្រើអំណាចរបស់លោក ដើម្បីកើបលុយមកវិញទេឬ? រឿងនេះជារឿងធម្មតារបស់អ្នកកាន់អំណាច ទោះបីនៅក្នុងនគរណា ក្នុងយុគណាក៏ដោយ។ ដូច្នេះ សាវ័កប៉ុលត្រូវស្នាក់នៅក្នុងចំណោមសំបុកចោរ និងសំបុកមនុស្សដែលមានកិរិយាសាហាវយង់ឃ្នង ដូចគម្ពីរចែងថា កណ្តាលហ្វូងស្វាន។

**នោះប៉ុលឆ្លើយថា ខ្ញុំប្របាទឈរនៅមុខទីជំនុំជំរះក្តីនៃសេសារ ជាកន្លែងដែលគួរជំនុំជំរះខ្ញុំប្របាទ ខ្ញុំប្របាទគ្មានធ្វើខុសអ្វីនឹងពួកសាសន៍យូដាទេ ដូចជាព្រះតេជព្រះគុណក៏ជ្រាបច្បាស់ហើយ (កិច្ចការ២៥:១០)។**

អ្នកខ្លះយល់ថា បើសាវ័កប៉ុលមិនរើក្តីទៅអោយព្រះរាជាសេសារកាត់ទោសទេ សាវ័កប៉ុលប្រហែលជាគេដោះអោយរួចខ្លួននៅក្រុងសេសារា ក្រោមការគ្រប់គ្រងរបស់លោកចៅហ្វាយខេត្តភេស្ទុស។ ប៉ុន្តែ បើលោកអ្នកនៅក្នុងចំណោមមនុស្សទាំងនោះ សូមយល់ថា លោកភេស្ទុសក៏ជាអ្នកនយោបាយមួយរូបដែរ។ អ្នកនយោបាយរូបនេះ យកសាវ័កប៉ុលធ្វើជាកូនអុក ដើម្បីសម្រេចទិសដៅនយោបាយរបស់ខ្លួន។ ពួកគណៈសង្ឃមិនខ្លាចនឹងសូកប៉ាន់ ដើម្បីទិញទឹកចិត្តចៅហ្វាយខេត្តនេះទេ។ បើសាវ័កប៉ុលមិនប្រើអំណាចរបស់លោកជាសញ្ជាតិរ៉ូម លោកច្បាស់ជាត្រូវពួកសាសន៍យូដាយកទៅសម្លាប់ បន្ទាប់ពីសូកប៉ាន់ដល់ចៅហ្វាយខេត្តរួចហើយ។ សាវ័កប៉ុលត្រូវទៅទីក្រុងរ៉ូម ដើម្បីធ្វើបន្ទាល់ពីព្រះអម្ចាស់យេស៊ូវនៅទីនោះទៀត។ ដូច្នេះ ខ្ញុំមិនបន្ទោសសាវ័កប៉ុល ដោយលោកសម្រេចចិត្តថា ត្រូវរើក្តីទៅថ្វាយព្រះរាជាសេសារឡើយ។

សព្វថ្ងៃនេះ មានមនុស្សខ្លះចង់ស្លាប់ក្នុងនាមព្រះអម្ចាស់យេស៊ូវគ្រិស្ត។ លោកអ្នកបម្រើព្រះយេស៊ូវ មិនចាំបាច់ធ្វើខ្លួនអោយទៅជាអ្នកមានគ្រោះថ្នាក់បែបនោះទេ។ ព្រះជាម្ចាស់ក៏មិនទាមទារអោយមនុស្សគ្រប់រូប ត្រូវធ្វើយ៉ាងដូច្នោះឡើយ។ ដូច្នេះ បើមិនចាំបាច់ សូមកុំបណ្តោយខ្លួនអោយត្រូវស្លាប់ ដោយសម្អាងថា ស្លាប់ក្នុងនាមព្រះយេស៊ូវនោះអោយសោះ។ មានពេលដែលមនុស្សណាមួយត្រូវស្លាប់ដោយជំនឿរបស់ខ្លួនជាពិតប្រាកដ ប៉ុន្តែ មិនមែនមនុស្សគ្រប់រូបសុទ្ធចាំបាច់ត្រូវស្លាប់ដោយជំនឿរបស់ខ្លួនក្នុងព្រះនាមព្រះយេស៊ូវទេ។

មុននឹងព្រះអង្គបញ្ជូនសាវ័កប៉ុលទៅទីក្រុងរ៉ូម ទ្រង់រំឭកដល់សាវ័កប៉ុលអំពី

ដំណើរនេះ នៅក្នុងគម្ពីរកិច្ចការ២៣:១១។ ឥឡូវ ពេលវេលាដែលត្រូវធ្វើដំណើរទៅទីក្រុងរ៉ូម បានមកដល់ហើយ។ គេចងលោកដោយច្រវាក់ មុននឹងអោយលោកធ្វើដំណើរទៅទីក្រុងរ៉ូម។ នៅពេលព្រះអម្ចាស់មានបន្ទូលទៅសាវ័កប៉ុល ត្រូវទៅទីក្រុងរ៉ូម ព្រះអង្គមិនបានមានបន្ទូលមកកាន់សាវ័កប៉ុលថា លោកត្រូវធ្វើដំណើរទៅដោយបែបណានោះទេ (សូមអានគម្ពីររ៉ូម១:៩-១០,១៥:៣-៣២)។ ការធ្វើដំណើរទៅទីក្រុងរ៉ូម គឺជាព្រះហឫទ័យបំណងរបស់ព្រះចំពោះជីវិតលោក។

> **បើសិនជាខ្ញុំប្របាទបានធ្វើអ្វីខុស ឬដែលគួរនឹងស្លាប់ នោះខ្ញុំប្របាទក៏យល់ព្រមនឹងស្លាប់ឥតប្រកែក តែបើរឿងដែលគេចោទខ្ញុំប្របាទមិនពិតវិញ នោះគ្មានអ្នកណាអាចនឹងបញ្ជូនទៅឱ្យគេបានឡើយ ខ្ញុំប្របាទសូមប្ដឹងរឿងនេះដល់សេសារវិញ (កិច្ចការ២៥:១១)។**

សូមយើងពិចារណាបន្តិចអំពីដំណើរ ដែលព្រះជាម្ចាស់រៀបចំជីវិតសាវ័កប៉ុលអោយទៅទីក្រុងរ៉ូម។ សាសន៍រ៉ូម គេជឿថាមានយុត្តិធម៌ណាស់។ ប៉ុន្តែ សាវ័កប៉ុលជាសាសន៍រ៉ូម លោកមិនបានទទួលដោះស្រាយរឿងលោកដោយយុត្តិធម៌ទេ។ ព្រះអង្គចង់អោយសាវ័កប៉ុលឡើងទៅទីក្រុងរ៉ូម ដើម្បីធ្វើទីបន្ទាល់ពីព្រះនាមរបស់ព្រះអង្គ។ ព្រះអង្គអនុញ្ញាតអោយសាវ័កប៉ុលប្រើសិទ្ធិជាសញ្ជាតិរ៉ូម ដើម្បីសម្រេចកិច្ចការនោះ។ ប៉ុន្តែ

មិនមែនមនុស្សដែលមានសញ្ញាតិរ៉ូមទាំងអស់ សុទ្ធតែមានឱកាសដូចសាវ័កប៉ុលឡើយ។ រឿងនេះជារឿងរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ប្រើមនុស្សម្នាក់នេះដោយវិធីនេះ ប្រើមនុស្សម្នាក់ទៀតដោយវិធីនោះវិញ។ ឯយើងជាកូនរបស់ព្រះអង្គ ចាំបាច់ត្រូវចុះចូលជាមួយនឹងព្រះអង្គតាមផែនការរបស់ទ្រង់គ្រប់ពេលគ្រប់វេលា។

ចំពោះលោកអ្នកបងប្អូនវិញ បើព្រះជាម្ចាស់ចង់អោយបម្រើព្រះអង្គ តាមផែនការរបស់ទ្រង់ តើបងប្អូនព្រមដែរឬទេ? ផែនការដែលព្រះអម្ចាស់ប្រើលោកអ្នកប្រហែលជាមិនដូចមនុស្សម្នាក់ទៀត ដែលព្រះអម្ចាស់ប្រើនោះទេ។ ម្នាក់ទៀតដែលព្រះអម្ចាស់ប្រើ គេមានបានគ្រប់ជំពូក។ ចំណែកឯផែនការដែលព្រះអង្គម្នាក់ទៀត ទ្រង់មិនអោយអ្នកនោះមានបានបរិបូរឡើយ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះអង្គសម្រេចផែនការរបស់ព្រះអង្គ តាមរយៈអ្នកទាំងពីរនោះ។ តើលោកអ្នកបងប្អូនព្រមចុះចូលតាមព្រះអង្គ ដោយរបៀបនេះដែរ ឬមួយយ៉ាងណា? នៅក្នុងដៃរបស់លោកអ្នកមានអ្វី ព្រះជាម្ចាស់ប្រើរបស់នោះសម្រាប់សម្រេចទិសដៅរបស់ទ្រង់ហើយ។ ព្រះអង្គមិនដែលភាន់ច្រឡំដោយប្រការណាទេ។ សូមចុះចូលនៅចំពោះផែនការរបស់ទ្រង់ចុះ។

**ក្រោយដែលភេស្ទុសបានពិគ្រោះនឹងក្រុមជំនុំ នោះក៏ឆ្លើយថា ឯងបានសូមប្តឹងក្តីនេះដល់សេសារវិញ បើដូច្នេះ ឯងត្រូវទៅដល់សេសារចុះ (កិច្ចការ២៥:១២)។**

លោកភេស្ទុសក៏យល់ព្រមតាមសំណើររបស់សាវ័កប៉ុល ក្នុងការសូមអោយបញ្ជូនលោកទៅទទួលការកាត់ទោសពីព្រះរាជាសេសារវិញ។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"